# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូចិនមកពីទីក្រុង **Xiamen** ខេត្ត **Fujian** នៃប្រទេសចិន





នៅព្រឹកថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៦ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូចិនមួយក្រុមមកពី ទីក្រុង Xiamen ខេត្ត Fujian នៃប្រទេសចិន ដឹកនាំដោយលោក **Yao Jianhong** អគ្គនាយករង នៃការិយាល័យកិច្ចការក្រៅប្រទេសចិននៃទីក្រុង Xiamen ប្រទេសចិន និងតំណាងឱ្យសមាគមត្រកូលអ៊ឹង (Huang) ប្រចាំទីក្រុងXiamen ដើម្បីពិភាក្សា ការងារនៅទីស្តីការក្រសួង ។



ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងបានលើកឡើងពីទំនាក់ទំនង ដ៏ល្អនិងយូរអង្វែង រវាងកម្ពុជា–ចិន ។ ជំនួបនាថ្ងៃនេះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ មានជំនឿថា ភាគីទាំងពីរ នឹងពង្រឹងបានថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការកាន់តែរឹងមាំ ដើម្បីផលប្រយោជន៍ទៅវិញទៅមក ។

លោក Yao Jianhong ប្រធានប្រតិភូមកពីទីក្រុង Xiamen បានវាយតម្លៃខ្ពស់ចំពោះភាពរីកចម្រើនលើគ្រប់វិស័យរបស់កម្ពុជា ។ ក្នុងនោះទំនាក់ទំនងរវាងកម្ពុជា និង ទីក្រុង Xiamen ក៏ត្រូវបានពង្រឹងឥតឈប់ឈរ តាមរយៈការដោះដូរពាណិជ្ជកម្ម និងការចូលរួមតាំងពិព័រណ៍ផ្សេងៗរបស់កម្ពុជានៅទីក្រុង Xiamen ។ ជំនួបថ្ងៃនេះ ប្រតិភូរបស់លោកបានផ្តោតលើបញ្ហាមួយចំនួនដូចជា:អញ្ជើញភាគីកម្ពុជាចូលរួម ក្នុងពិព័រណ៍វប្បធម៌ ណានយ៉ាងលើកទី៥–ការសម្ពោធការបង្កើតសមាគមពាណិជ្ជកម្ម Fujian នៅកម្ពុជា–ការផ្សព្វផ្សាយតំបន់ពាណិជ្ជកម្មសេរីទីក្រុង Xiamen –និងស្នើដល់កម្ពុជាពិនិត្យលទ្ធភាពក្នុងការបង្កើតអគ្គកុងស៊ុលរបស់ខ្លួនប្រចាំទីក្រុង Xiamen ដែលភាគីចិននឹងជួយសម្រួលគ្រប់បែបយ៉ាងជាពិសេសទីតាំងអគារដែលបានសាងសង់រួចហើយ ។ ជាមួយគ្នានេះ លោក Yao Jianhong ក៏បានអញ្ជើញ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ អញ្ជើញ ទៅទស្សនៈកិច្ច នៅទីក្រុង **Xiamen** ក្នុងនាមឯកឧត្តម ជាទេសរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និង ជាប្រធានកិត្តិយសមាគមត្រកូល **អ៊ឹង** នៅកម្ពុជា តាមពេលវេលាសមស្របណាមួយ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសាទរ និងផ្តល់សារៈសំខាន់ ចំពោះចំណុចទាំងឡាយដែលបានលើកឡើងខាងលើ ពីព្រោះនឹងជួយជម្រុញបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការនៃភាគីទាំងពីរ ជាពិសេសលើវិស័យ សេដ្ឋកិច្ច ពាណិជ្ជកម្ម ឧស្សាហកម្ម វប្បធម៌ និងទេសចរណ៍ជាដើម ។






厚德載物